ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង ៖ ០០៦/១៧ - គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៧**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ឈីវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ទួន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត**

អាសយដ្ឋាន ៖ ភូមិវិហារសួគ៌ជើង ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៨៩ ៦៨៦ ៨៩៣ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | | |
|---|---|---|
| ១- | លោកស្រី សៀង រចនា | ប្រធានរដ្ឋបាល |
| ២- | លោកស្រី ឈិញ សេដ្ឋា | ជំនួយការរដ្ឋបាល |
| ៣- | លោក តុប ពិសី | ជំនួយការរដ្ឋបាល |
| ៤- | លោក សយ ធារិទ្ធ | មន្ត្រីច្បាប់ GMAC |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **តំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត**

អាសយដ្ឋាន ៖ ភូមិវិហារសួគ៌ជើង ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៨៦ ៦៨១៣ ៥៣១ ទូរសារ ៖ គ្មាន



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥.២៣ ៨៨១ ៨២៤

No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824

E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិត ៖

១- លោក យុត គឿន　　　　　　　　កម្មករដេរគំរូ

២- លោកស្រី កាក់ បូរ៉ានី　　　　　　កម្មករដេរគំរូ

៣- លោក ប៊ុក វ៉ាត　　　　　　　　　កម្មករដេរគំរូ

៤- លោក ឈិន ផល្លី　　　　　　　　ជាង

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យនាយកក្រុមហ៊ុនមានការតំឡើងប្រាក់ឈ្នួលឱ្យបាន ១៣ ដុល្លារ បូកបញ្ចូលលើប្រាក់ខែគោលនៅឆ្នាំ២០១៧ ខែមករា ។

- សម្រាប់ការទាមទាររបស់បងប្អូនកម្មករ កម្មការិនីផ្នែកដេរគំរូ ដែលស្នើសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគោលបន្ថែម ១៣ ដុល្លារ លើប្រាក់ឈ្នួលគោលឆ្នាំ២០១៦ ដែលមានចំនួន ១៦០ ដុល្លារ គឺភាគីក្រុមហ៊ុនបានផ្តល់ជូន ចំនួន ១០ ដុល្លារ ដូច្នេះ ប្រាក់ឈ្នួលគោលសម្រាប់កម្មករ កម្មការិនីផ្នែកដេរគំរូសម្រាប់ឆ្នាំ២០១៧ មានចំនួន ១៧០ ដុល្លារ ប៉ុន្តែ ភាគីកម្មករ កម្មការិនីមិនព្រមទទួលយកឡើយ ដោយនៅរក្សាជំហរទាមទារ ១៣ ដុល្លារ ដដែល ។

- ភាគីក្រុមហ៊ុន ៖ ដោយសារបងប្អូនកម្មករ កម្មការិនីមិនព្រមទទួលយកប្រាក់ឈ្នួលគោលបន្ថែម ១០ ដុល្លារ លើប្រាក់ឈ្នួលគោលចាស់ ១៦០ ដុល្លារ ដូច្នេះ ក្រុមហ៊ុននៅរក្សាការផ្តល់ប្រាក់ឈ្នួលគោលសម្រាប់ឆ្នាំ២០១៧ ចំនួន ១៦០ ដុល្លារ ដដែល ដោយរង់ចាំការដោះស្រាយរួចរាល់សិន ហើយលទ្ធផលនៃការដោះស្រាយបែបណា ក្រុមហ៊ុនអនុវត្តបែបនោះ ហើយការអនុវត្ត គឺចាប់ធ្វើក្រោយថ្ងៃដោះស្រាយចប់ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២២ កប/ប្រក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ (អាណត្តិទី១៤) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត លេខ ២៨១ ក.ប/ក.ណ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែមករា ឆ្នាំ ២០១៧ ។

THE ARBITRATION COUNCIL

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៧ (វេលាម៉ោង ០៨ និង ០០ នាទី ព្រឹក ) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតប្រចាំក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីតធីត ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ ស្តីពីកម្មករនិយោជិតផ្នែកដេរតំរូវទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលគោលបន្ថែម ចំនួន ១៣ ដុល្លារអាមេរិក លើប្រាក់ឈ្នួលគោលឆ្នាំ២០១៦ ដែលមានចំនួន ១៦០ ដុល្លារអាមេរិក ។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះ និងធ្វើការផ្សះផ្សាវិវាទ ចំនួន ០១ ចំណុចនេះ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ។ ចំណុចមិនសះជា ០១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៧ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លេខ ២៨១ ក.ប/ក.ណ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ ។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ០១ ចំណុចនេះ នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៧ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក ។ ភាគីទាំងពីរ មានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជា ចំនួន ០១ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាចំណុចវិវាទនេះ ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ទៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ វិញ ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ របស់នាយកក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត ផ្ទេរសិទ្ធិជូន លោកស្រី សៀង រចនា និងលោក សាយ ធារិទ្ធ ។

២- សារណាការពាររបស់តំណាងក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត គោរពជូន ប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ។

៣- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត លេខ ៩៣៥៤ ពណ.ចបព ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ ។

៤- ប័ណ្ណពន្ធប៉ាតង់ ឆ្នាំ២០១៦ របស់ក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត លេខ ១០៨២៤/២០១៦ ប/អពដ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ។

៥- លក្ខន្តិកៈក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត តំកល់ទុកលេខ ០៣២០៤/២០១១ ពណ.ចបព ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

៦- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត បានឃើញ និងបញ្ជាក់ថាត្រឹមត្រូវដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល លេខ ០៩៨ ក.ប.ក.ណ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ ។

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត ចុះថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៧ ។

៨- លិខិតលេខ CMI-០៣០១៧-០១៧ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត គោរពជូន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ស្តីពីស្នើសុំអញ្ជើញមន្ត្រីការងារចូលរួមសម្របសម្រួលការទាមទារតំឡើងប្រាក់ឈ្នួលគោលអប្បរមាសម្រាប់ឆ្នាំ ២០១៧ របស់ផ្នែកដេរគំរូ ។

៩- កំណត់ហេតុចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីកិច្ចប្រជុំរវាងតំណាងក្រុមហ៊ុន និងប្រតិភូពេញសិទ្ធិសហជីពមូលដ្ឋាន លើបញ្ហាមិនសុខចិត្តនឹងការផ្តល់ប្រាក់ឈ្នួលតម្លើង ១០ ដុល្លារ លើប្រាក់ខែគោល ឆ្នាំចាស់ ២០១៦ សម្រាប់ផ្នែកដេរគំរូទាំងអស់ ។

១០- កំណត់ហេតុចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីកិច្ចប្រជុំរវាងតំណាងក្រុមហ៊ុន លោកស្រី សៀង រចនា និងប្រតិភូពេញសិទ្ធិ សហជីពមូលដ្ឋាន លើបញ្ហាមិនសុខចិត្តនឹងការផ្តល់ប្រាក់ឈ្នួលតម្លើង ១០ ដុល្លារ លើប្រាក់ខែគោល ឆ្នាំចាស់ ២០១៦ សម្រាប់ផ្នែកដេររគំរូទាំងអស់ ។

១១- កំណត់ហេតុចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ ដោយទទួលបានការឯកភាពគ្នាដើម្បីអញ្ជើញ ស្តីពីការពន្យល់ និងបកស្រាយប្រកាសលេខ ៤១៤ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៧ របស់មន្ត្រីច្បាប់នៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)។

១២- តារាងប្រាក់ឈ្នួលរបស់កម្មករនិយោជិត។

១៣- តារាងប្រាក់បៀវត្សបុគ្គលិកកម្មករ និងលំអិតប្រាក់ខែ។

១៤- ប្រកាសលេខ ៤១៤ ក.ប/ប្រ.ក ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំ២០១៧។

១៥- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពការងារដើម្បីកម្ពុជាក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត លេខ ០១៨/១៥ ក.ប/វ.ប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥។

១៦- លិខិតលេខ ១៨១ កប/អក/វក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ របស់នាយកដ្ឋានវិវាទការងារ ជម្រាបមក លោកប្រធានសហជីពការងារដើម្បីកម្ពុជាក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីធីត ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី។

១៧- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីតធីត បានចុះបញ្ជិកាលេខ ៣០៦៣ ក.ប/វក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣។

១៨- របាយការណ៍កិច្ចប្រជុំរបស់គណៈកម្មាធិការការងារ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រុមហ៊ុន គ្រីស្តល់ ម៉ាទីន (ខេមបូឌា) លីមីតធីត។

១៩- យោបល់ជំទាស់របស់និយោជក ទៅនឹងភស្តុតាងរបស់តំណាងភាគីកម្មករនិយោជិតសំណុំរឿងលេខ ០០៦/១៧-គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីតធីត ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតផ្ទេរសិទ្ធិ និងដោះស្រាយ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ របស់កម្មករ កម្មការិនីផ្នែកគំរូសូមគោរពចូលមក លោកតំណាងកម្មករ និងកម្មករ កម្មការិនីដែលមានឈ្មោះ ឈិន ផល្លី ឃុត គឿន ប៊ុង វ៉ាត និងឈ្មោះ កាក់ បូរ៉ានី។

២- កំណត់ហេតុរបស់កម្មករ កម្មការិនីកាត់ដេរនៅក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន ៧ NG ទី៨។

៣- កំណត់ហេតុកិច្ចប្រជុំតំណាងកម្មករ កម្មការិនី នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៦ វេលាម៉ោង ២ ល្ងាច បានជួបជាមួយផ្នែករដ្ឋបាលបានលើកឡើងអំពីប្រាក់ខែ ដែលក្រសួងចេញសេចក្តីប្រកាសឱ្យប្រើប្រាស់នៅឆ្នាំ២០១៧ ខែមករា។

៤- កំណត់ហេតុរបស់កម្មករ កម្មការិនីកាត់ដេរសម្លៀកបំពាក់ផ្នែកគំរូនៅក្នុងឆ្នាំ២០១៥ ខែធ្នូ ទី១៦ វេលាម៉ោង ០៩៖០៨ នាទី ព្រឹក ប្រជុំជាមួយប្រធានរដ្ឋបាលផ្នែកធនធានមនុស្ស។

៥- លិខិតស្នើសុំចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ របស់កម្មករកម្មការិនីកាត់ដេរផ្នែកគំរូ និងផ្នែកផ្សេងៗ សូមឱ្យនាយកក្រុមហ៊ុន មានការតំឡើងប្រាក់ឈ្នួលឱ្យបាន ១៣ ដុល្លារ និងបញ្ចូលលើប្រាក់ខែគោលនៅឆ្នាំ២០១៧ ខែមករា។

៦- កំណត់ហេតុកិច្ចប្រជុំនៅក្នុងក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន ៧NG ទី៨ រួមជាមួយមន្ទីរការងារ និងប្រធានរដ្ឋបាល ព្រមទាំងតំណាងកម្មករ ធ្វើនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។

៧- តារាងប្រាក់បៀវត្សបុគ្គលិកកម្មករ និងលំអិតប្រាក់ខែ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីតធីត លេខ ២៨១ ក.ប/ក.ណ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីតធីត ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីតធីត របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល លេខ ០០១/១៧ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ០៤៩ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ០៥០ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន (ខេមបូឌា) លីមីតធីត (តទៅនេះឱ្យហៅថា "ក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន" គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការកាត់ដេរសម្លៀកបំពាក់ និងបានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម ក្រោមលេខ Inv. ២៨៤៧ E/២០១១ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១។ បច្ចុប្បន្នក្រុមហ៊ុន

នេះ ជួលកម្មករនិយោជិតចំនួនប្រហែលជា ៥១៦៩ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន)*។

- យោងតាមលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល លេខ ០០១/១៧ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧ បានបញ្ជាក់ថា ឈ្មោះ ១) ឃុត គឿន មុខងារដេរគំរូ ២) ឈិន ផល្លី មុខងារដេរគំរូ និង ៣) វ៉ុន ស្រីពៅ មុខងារដេរគំរូ និង ៤) ប៊ុក វ៉ាត មុខងារដេរគំរូ ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន ។
- នៅក្នុងសវនាការ ភាគីទាំងពីរទទួលស្គាល់ថា កម្មករនិយោជិត ឈិន ផល្លី គឺជាប្រតិភូបុគ្គលិកនៃក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន ។
- នៅក្នុងក្រុមហ៊ុន មានសហជីពការងារដើម្បីកម្ពុជាក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន ជាសហជីពដែលមានភាពជាតំណាងបំផុត ដែលបានទទួលវិញ្ញាបនបត្របញ្ជាក់ភាពជាតំណាងបំផុត លេខ ០១៨/១៥ ក.ប/វ.ប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ និងត្រូវមានសុពលភាពត្រឹមថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧ ។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកតម្លើងប្រាក់ឈ្នួល ចំនួន ១៣ ដុល្លារអាមេរិក បន្ថែមលើប្រាក់ឈ្នួល ចំនួន ១៦០ ដុល្លារអាមេរិក សម្រាប់ឆ្នាំ២០១៧ ដល់កម្មករនិយោជិតផ្នែកដេរគំរូ**

- *ភាគីទាំងពីរទទួលស្គាល់ថា ៖*
    - និយោជកសម្រេចផ្តល់ប្រាក់ឈ្នួល ចំនួន ១០ ដុល្លារអាមេរិក បន្ថែមលើប្រាក់ឈ្នួលគោល ចំនួន ១៦០ ដុល្លារអាមេរិក សម្រាប់ឆ្នាំ ២០១៧ ដល់កម្មករនិយោជិតផ្នែកដេរគំរូទាំង ៥១ នាក់ ។
    - ជាការអនុវត្តច្រើនឆ្នាំកន្លងមក និយោជកតែងតែផ្តល់ប្រាក់ឈ្នួលបន្ថែម ដល់កម្មករនិយោជិតផ្នែកគំរូ ចំនួន ២០ ដុល្លារអាមេរិក លើសប្រាក់ឈ្នួលគោលដែលនិយោជកផ្តល់ឱ្យកម្មករនិយោជិតធម្មតា ដោយផ្អែកលើប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង សម្រាប់ឆ្នាំនីមួយៗ ពោលគឺ និយោជកបានអនុវត្តដូចខាងក្រោម ៖
        - នៅឆ្នាំ២០១៣ កម្មករនិយោជិតធម្មតាទទួលបានប្រាក់ឈ្នួលគោល ចំនួន ៨០ ដុល្លារអាមេរិក ចំណែកឯកម្មករនិយោជិតផ្នែកដេរគំរូទទួលបានប្រាក់ឈ្នួលគោល ចំនួន ១០០ ដុល្លារអាមេរិក ។
        - នៅឆ្នាំ២០១៤ កម្មករនិយោជិតធម្មតាទទួលបានប្រាក់ឈ្នួលគោល ចំនួន ១០០ ដុល្លារអាមេរិក ចំណែកឯ កម្មករនិយោជិតផ្នែកដេរគំរូទទួលបានប្រាក់ឈ្នួលគោល ចំនួន ១២០ ដុល្លារអាមេរិក ។
        - នៅឆ្នាំ២០១៥ កម្មករនិយោជិតធម្មតាទទួលបានប្រាក់ឈ្នួលគោលចំនួន ១២៨ ដុល្លារអាមេរិក ចំណែកឯកម្មករនិយោជិតផ្នែកដេរគំរូទទួលបានប្រាក់ឈ្នួលគោល ចំនួន ១៤៨ ដុល្លារអាមេរិក ។

- នៅឆ្នាំ២០១៦ កម្មករនិយោជិតធម្មតាទទួលបានប្រាក់ឈ្នួលគោល ចំនួន ១៤០ ដុល្លារអាមេរិក ចំណែកឯ កម្មករនិយោជិតផ្នែកដេរគំរូទទួលបានប្រាក់ឈ្នួលគោល ចំនួន ១៦០ ដុល្លារអាមេរិក។

○ និយោជកតែងតែផ្តល់ប្រាក់ឈ្នួលបន្ថែមពីលើប្រាក់ឈ្នួលគោលដែលកំណត់ដោយប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ដល់កម្មករនិយោជិតផ្នែកប្រធានក្រុម កម្មករនិយោជិតផ្នែកជាង កម្មករនិយោជិតផ្នែកក្រណាត់ កម្មករនិយោជិតផ្នែកឃ្លាំងសំភារៈ និងកម្មករនិយោជិតផ្នែកគុណភាព ពោលគឺ ចំនួនទឹកប្រាក់ដែលត្រូវបន្ថែមមានដូចជា ចំនួន ១៣ ដុល្លារអាមេរិក ចំនួន ១០ ដុល្លារអាមេរិក ចំនួន ៧ ដុល្លារអាមេរិក និង ចំនួន ០៥ ដុល្លារអាមេរិក ហើយចំនួនទឹកប្រាក់ដែលត្រូវបន្ថែមនេះ មិនមានភាពទៀងទាត់ចំពោះក្រុមនីមួយៗឡើយ។

○ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ផ្នែកធនធានមនុស្សមានកិច្ចប្រជុំជាមួយកម្មករនិយោជិតស្តីពីការតម្លើងប្រាក់ឈ្នួលគោល ដល់កម្មករនិយោជិតផ្នែកគំរូ ឱ្យលើសពីប្រាក់ឈ្នួលគោលអប្បរមារបស់កម្មករនិយោជិតធម្មតា។

- ភាគីកម្មករនិយោជិតបានបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - ○ នៅក្នុងកិច្ចប្រជុំថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ និយោជកបានសន្យាផ្ទាល់មាត់ ប្រាប់កម្មករនិយោជិតឱ្យចងចាំរហូតថា ប្រាក់ឈ្នួលរបស់កម្មករនិយោជិតផ្នែកដេរគំរូ ត្រូវលើសប្រាក់ឈ្នួលកម្មករនិយោជិតធម្មតា ចំនួន ២០ ដុល្លារ ជារៀងរាល់ឆ្នាំ។
  - ○ និយោជកបានអនុវត្តផ្តល់ប្រាក់ឈ្នួលបន្ថែម ចំនួន ២០ ដុល្លារអាមេរិក ដល់កម្មករនិយោជិតផ្នែកដេរគំរូ តាំងពីឆ្នាំ២០១៣ ដូចនេះ កម្មករនិយោជិតមិនចង់បាត់បង់ផលប្រយោជន៍នោះទេ។
- ភាគីនិយោជកបានបញ្ជាក់ថា ៖
  - ○ នៅក្នុងកិច្ចប្រជុំថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ និយោជកបាននិយាយទាក់ទងទៅនឹងការតម្លើងប្រាក់ឈ្នួលសម្រាប់ឆ្នាំ២០១៦។ ដោយឡែក និយោជកមិនបានសន្យាថា នឹងផ្តល់ប្រាក់ឈ្នួលបន្ថែមដល់កម្មករនិយោជិតផ្នែកដេរគំរូ ត្រូវតែឱ្យលើសពីប្រាក់ឈ្នួលគោលកម្មករនិយោជិតធម្មតា ចំនួន ២០ ដុល្លារ ជារៀងរាល់ឆ្នាំនោះទេ។
  - ○ និយោជកមិនមានអនុវត្តន៍ជាគោលការណ៍ ឬបានចុះនៅក្នុងអនុសញ្ញារួមទាក់ទងនឹងការផ្តល់ប្រាក់ឈ្នួលបន្ថែម ចំនួន ២០ ដុល្លារអាមេរិក ដល់កម្មករនិយោជិតផ្នែកដេរគំរូនោះទេ។
  - ○ ការផ្តល់ប្រាក់ឈ្នួលបន្ថែមដែលមាន ចំនួន ០៥ ដុល្លារអាមេរិក ឬ ០៧ ដុល្លារអាមេរិក ឬ ១០ ដុល្លារអាមេរិក ឬ ១៣ ដុល្លារអាមេរិក ដល់កម្មករនិយោជិតផ្នែកប្រធានក្រុម កម្មករនិយោជិតផ្នែកជាង កម្មករនិយោជិតផ្នែកក្រណាត់ កម្មករនិយោជិតផ្នែកឃ្លាំងសំភារៈ និងកម្មករនិយោជិតផ្នែកគុណភាព គឺមានការប្រែប្រួលជារៀងរាល់ឆ្នាំ ពោលគឺ ការផ្តល់ជូនប្រាក់ឈ្នួលបន្ថែមដល់

កម្មករនិយោជិតក្រុមនីមួយៗ គឺអាស្រ័យទៅលើការងាររបស់កម្មករនិយោជិតនៅក្នុងក្រុមនោះ តាមរយៈការវាយតម្លៃផ្ទាល់របស់និយោជកក្រុមហ៊ុន។

- ការដែលនិយោជកបានផ្តល់ប្រាក់ឈ្នួលបន្ថែម ១០ ដុល្លារអាមេរិក លើប្រាក់ឈ្នួលគោល ១៦០ ដុល្លារអាមេរិក គឺមានភាពល្អប្រសើរជាងច្បាប់រួចទៅហើយ។ យ៉ាងណាមិញ ចំណុចវិវាទនៅក្នុងសេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំណុំរឿងលេខ ២៣៣/១៥ ដែលកម្មករនិយោជិតទាមទារឱ្យនិយោជកបូកប្រាក់ ចំនួន ២៨ ដុល្លារអាមេរិក ទៅក្នុងប្រាក់ឈ្នួលគោលដែលមានស្រាប់ ចំនួន ១០៥ ដុល្លារអាមេរិក សរុបចំនួន ១៣៣ ដុល្លារអាមេរិក ក្នុងមួយខែ នោះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចបដិសេធពិចារណាការទាមទារលើចំណុចវិវាទនោះដែរ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

មុននឹងពិចារណាចំណុចទាមទារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការបកស្រាយជាមុនសិន អំពីសិទ្ធិរបស់ម្ចាស់បណ្តឹង និងអ្នកតំណាង ក្នុងសំណុំរឿងនេះ ដូចខាងក្រោម ៖

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *“ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។”*។

នៅក្នុងសំណុំរឿងលេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា *“យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃមាត្រាខាងលើនេះ មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬ គ្រឹះស្ថានរបស់ខ្លួន។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះសំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលអាចធ្វើជាតំណាងឱ្យកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។”(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមអង្គហេតុ នៅក្នុងក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន មានសហជីពការងារដើម្បីកម្ពុជាក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន ជាសហជីពដែលមានភាពជាតំណាងបំផុត ដែលបានទទួលវិញ្ញាបនបត្របញ្ជាក់ភាពជាតំណាងបំផុត លេខ ០១៨/១៥ ក.ប/វ.ប ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ និងត្រូវមានសុពលភាពត្រឹមថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧។ ដោយឡែក នៅក្នុងសំណុំរឿងនេះ កម្មករនិយោជិតបានផ្ទេរសិទ្ធិជូនកម្មករនិយោជិត ០៤ នាក់ ១) ឃុត គឿន ២) ឈិន ផល្លី និង ៣) កាក់ បូរ៉ានី និង ៤) ប៊ុក វ៉ាត តាមរយៈលិខិតផ្ទេរសិទ្ធិ និងដោះស្រាយ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ

២០១៧ ដោយមានឈ្មោះ និងស្នាមមេដៃរបស់កម្មករនិយោជិតផ្នែកដេរគំរូ ចំនួន ៥០ នាក់។ ក្រៅពីនេះ មានលិខិតបញ្ជាក់អ្នកតំណាង ដោយមានកម្មករនិយោជិត ១) ឃុត គឿន មុខងារដេរគំរូ ២) ឈិន ផល្លី មុខងារដេរគំរូ និង ៣) កាក់ បូរ៉ានី មុខងារដេរគំរូ និង ៤) ប៉ឹក វ៉ាត មុខងារដេរគំរូ តំណាងឱ្យភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល លេខ ០០១/១៧ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧។

ហេតុនេះ យោងតាមការបកស្រាយខ្លឹមសារនៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០១៦ ខាងលើ ដោយសារក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន មានសហជីពដែលមានភាពជាតំណាងបំផុតហើយ ក្រុម-ប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំង ០៤ នាក់ ដែលត្រូវបានបញ្ជាក់ជាអ្នកតំណាងកម្មករនិយោជិតនៅក្រុមហ៊ុន គ្រីស្តាល់ ម៉ាទីន មិនមានសិទ្ធិក្នុងការតំណាងឱ្យកម្មករនិយោជិត ដើម្បីនាំយកវិវាទការងាររួមក្នុងការដោះស្រាយនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាសំណុំរឿងលេខ ០០៦/១៧-គ្រីស្តាល់ ម៉ាទីន។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ៖

## សម្រេច

- បដិសេធពិចារណាសំណុំរឿងលេខ ០០៦/១៧-គ្រីស្តាល់ ម៉ាទីន។

**ប្រភេទនៃសេចក្តីបង្គាប់៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍ អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក៖**

ឈ្មោះ៖ **ឈឹម គិរមេ្យ**

ហត្ថលេខា៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖**

ឈ្មោះ៖ **ឡូន ស៊ីផាន់**

ហត្ថលេខា៖------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល៖**

ឈ្មោះ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា៖ ------------------------------